00866089

E185/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 04 / 12 / 2012
ម៉ោង (Time/Heure): 09:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ

**Case File/Dossier No. 002/19-09-2007-ECCC/TC**

ចំពោះមុខ: ចៅក្រម **និល ណុន** ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម **យ៉ា សុខន**
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម **យូរ ឧត្តរា**

កាលបរិច្ឆេទ: ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០១២
ភាសាដើម: ខ្មែរ/អង់គ្លេស/បារាំង
ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

# សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅក្នុងឧបសម្ព័ន្ធ A6-A11 និង A14-A20 របស់សហព្រះរាជអាជ្ញា និងឯកសារដែលបានស្នើឡើងដោយភាគីផ្សេងទៀត

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**
នួន ជា
អៀង សារី
ខៀវ សំផន

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ

**មេធាវីជនជាប់ចោទ**
សុន អរុណ

Elisabeth SIMONNEAU FORT

Michiel PESTMAN
Victor KOPPE
**អាង ឧត្តម**
Michael G. KARNAVAS
**គង់ សំអុន**
Arthur VERCKEN
Jacques VERGÈS
Anta GUISSE

## ១. សេចក្ដីផ្ដើម

1. សហព្រះរាជអាជ្ញា មានបំណងដាក់ឯកសារទាំងអស់របស់ខ្លួនក្នុងឧបសម្ព័ន្ធ A6-A11 និង A14-A20 នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[1]។ អង្គជំនុំជម្រះសាលាដំបូង ក៏ទទួលបានផងដែរនូវសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីស្នើដាក់ឯកសារចំនួន១០ នៅចំពោះមុខអង្គជំនុំជម្រះ, សំណើដាក់ឯកសារ D222/1.17 របស់អៀង សារី និងសំណើដាក់ឯកសារចំនួន ៧៨ របស់ខៀវ សំផន[2]។ សេចក្ដីសម្រេចនេះត្រូវបានធ្វើឡើង បន្ទាប់ពីសវនាការដោយផ្ទាល់មាត់ពាក់ព័ន្ធនឹងការជំទាស់ទៅនឹងការទទួលយកឯកសារទាំងនេះ ដោយអនុលោមតាមវិធាន ៨៧ (៣) នៃវិធានផ្ទៃក្នុង និងសម្រេចថាតើឯកសារទាំងនេះ បំពេញលក្ខខណ្ឌនៃឯកសារ ដែលត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដូចមានចែងក្នុងអនុវិធាននោះដែរ ឬយ៉ាងណា។

---

[1] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងស្នើសុំឯកសារ ដែលទាក់ទិននឹងដំណាក់កាលដំបូងនៃការជំនុំជម្រះលើអង្គសេចក្ដី ឯកសារលេខ E109/4 ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ ("សំណើរបស់សហព្រះរាជអាជ្ញា")។ ឧបសម្ព័ន្ធ ៦៖ ប្រវត្តិរូបកម្ពុជាប្រជាធិបតេយ្យ (E109/4.6), ឧបសម្ព័ន្ធ ៧៖ កំណត់ត្រាពាណិជ្ជកម្មកម្ពុជាប្រជាធិបតេយ្យ (E109/4.7), ឧបសម្ព័ន្ធ ៨៖ កំណត់ត្រាស្រុកត្រាំកក់ (E109/4.8), ឧបសម្ព័ន្ធ ៩៖ កំណត់ត្រាអ្នកទោស ស-២១ (E109/4. 9), ឧបសម្ព័ន្ធ ១០៖ ចម្លើយសារភាពនៅស-២១ (E109/4.10), ឧបសម្ព័ន្ធ ១១៖ ប្រតិចារិកសវនាការ សំណុំរឿង ០០១ (E109/4.11), ឧបសម្ព័ន្ធ ១៤៖ របាយការណ៍កំណត់អត្តសញ្ញាណទីកន្លែង (E109/4.14), ឧបសម្ព័ន្ធ ១៥៖ ផែនទី និងរូបថត (E109/4.15), ឧបសម្ព័ន្ធ ១៦៖ ខ្សែអាត់សំឡេង និងវីដេអូ (E109/4.16), ឧបសម្ព័ន្ធ ១៧៖ ការធ្វើទំនាក់ទំនងអន្តរជាតិ (E109/4.17), ឧបសម្ព័ន្ធ ១៨៖ សេចក្ដីរាយការណ៍ព័តមានអន្តរជាតិ (E109/4.18), ឧបសម្ព័ន្ធ ១៩៖ អត្ថបទសិក្សាស្រាវជ្រាវ របាយការណ៍វិភាគ និងសៀវភៅ (E109/4.19), ឧបសម្ព័ន្ធ ២០៖ របាយការណ៍ស្ដីពីការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស (E109/4.20)។

[2] *សូមមើល* ឧបសម្ព័ន្ធ៧ក របស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី – ឯកសារដែលមាននៅក្នុងសំណុំរឿង ដែលត្រូវដាក់នៅចំពោះអង្គជំនុំជម្រះសាលាដំបូង E109/2.1 ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១១ (ឯកសារចំនួន ១៥ ក្នុងចំណោមឯកសារនៅក្នុងឧបសម្ព័ន្ធនេះ ជាន់គ្នានឹងឯកសារដែលស្នើឡើងដោយសហព្រះរាជអាជ្ញា ឬបានដាក់នៅពោះមុខអង្គជំនុំជម្រះរួចហើយ)។ បញ្ជីភស្តុតាង និងឯកសាររបស់លោក អៀង សារី លើប្រធានបទទាំងបួនសម្រាប់ដំណាក់កាលដំបូងនៃការជំនុំជម្រះលើអង្គសេចក្ដី E109/6.2 ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១១ (D313/1.2.2 ត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ជាឯកសារ E3/88) និងឯកសារសម្រាប់សវនាការដំណាក់កាលដំបូង E109/1.1 ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ (ឯកសារខាងក្រោមចំនួន ១០ ត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចហើយ គឺឧបសម្ព័ន្ធ D28 (E3/21), 13.2 (E3/182), D201/8 (E3/43), D200/3 (E3/64), D200/9 (E3/67), D125/160 (E3/58), D167 (E3/42), D199/20 (E3/96), D166/166 (E3/35) និង D91/9 (E3/104))។ *សូមមើលផងដែរ* បច្ចុប្បន្នភាពទៅលើអនុស្សរណៈស្ដីពីសវនការលើឯកសារនៅដំណាក់កាលបន្ទាប់ (ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី ១២ ដល់ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២) E172/5, ថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០១២ កថាខណ្ឌ ៣។

## ២. ប្រវត្តិនីតិវិធី

2. កាលពីថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាបានដាក់ឧបសម្ព័ន្ធចំនួន ២០ នៃឯកសារដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[3]។ បន្ទាប់មក ក្រុមមេធាវីការពារក្តីនីមួយៗ បានដាក់សារណាជំទាស់នឹងឯកសារមួយចំនួនក្នុងចំណោមឯកសារទាំងនោះ[4]។

3. ក្នុងអំឡុងពេលសវនាការពី ថ្ងៃទី ១៦ ដល់ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១២ ("សវនាការដេញដោលលើឯកសារភស្តុតាងលើកទីមួយ")[5] ភាគីត្រូវបានផ្តល់ឱកាសលើកដំបូងដើម្បីដាក់ការជំទាស់ទៅនឹង

---

[3] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (បញ្ជាក់អត្តសញ្ញាណឯកសារពាក់ព័ន្ធនឹងចំណុចអង្គហេតុដែលត្រូវធ្វើសវនាការដំណាក់កាលដំបូងពីចំណោមឯកសារដែលត្រូវបានដាក់បញ្ចូលក្នុងបញ្ជីឯកសារដើមរបស់សហព្រះរាជអាជ្ញា (បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា សម្រាប់សវនាការស្របតាមវិធាន ៨០(៣) ឯកសារលេខ E9/31 ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១)។ ឧបសម្ព័ន្ធ ២១ ជាបញ្ជីឯកសារដែលមិនមានក្នុងសំណុំរឿង និងមិនបានដាក់បញ្ចូលក្នុងបញ្ជីសហព្រះរាជអាជ្ញា ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១។ ឯកសារនៅក្នុងឧបសម្ព័ន្ធនោះ ត្រូវបានដោះស្រាយក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត ឯកសារលេខ E190 ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១២ (សេចក្តីសម្រេចទាក់ទងនឹងឯកសារថ្មីៗ)។

[4] ការជំទាស់ ការកត់សម្គាល់ និងការជូនដំណឹងទាក់ទងនឹងឯកសារផ្សេងៗដែលត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារលេខ E131/1/9 ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ ("ការជំទាស់របស់នួន ជា ចំពោះការទទួលយកឯកសារផ្សេងៗ")។ ការជំទាស់ទៅនឹងឯកសារ និងសារណាបន្ថែមអនុលោមតាមវិធាន ៩២ ឯកសារលេខ E131/1/12 ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១២ ("ការជំទាស់របស់ នួន ជា ចំពោះការទទួលយកឯកសារបន្ថែម")។ សេចក្តីជំទាស់មិនទទួលយកបញ្ជីឯកសារសេសសល់ដែលដាក់ដោយភាគីផ្សេងទៀតសម្រាប់ការជំនុំជម្រះដំណាក់កាលដំបូងទាំងបួន ឯកសារលេខ E131/1/11 ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១២ ("ការជំទាស់របស់ខៀវ សំផន ចំពោះការទទួលយកឯកសារ")។ ការជំទាស់របស់ អៀង សារី ចំពោះការទទួលយកឯកសារមួយចំនួនពីការិយាល័យសហព្រះរាជអាជ្ញាសម្រាប់សវនាការបួនវគ្គដំបូង ឯកសារលេខ E131/1/10 ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១២ ("ការជំទាស់របស់ អៀង សារី ចំពោះការទទួលយកឯកសារ")។ *សូមមើលផងដែរ* បញ្ជីឈ្មោះសាក្សីសម្រាប់ការជំនុំជម្រះនៅដំណាក់កាលដំបូង ពេលវេលាកំណត់សម្រាប់ការតវ៉ាអំពីការទទួលយកឯកសារ និងវត្ថុតាង និងចម្លើយតបទៅនឹងសំណើ ដែលមានលេខឯកសារ E109/5 ឯកសារលេខ E131/1 ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១។

[5] ប្រតិចារិក ថ្ងៃទី ១៧-១៩ ខែ មករា ឆ្នាំ ២០១២។ ក្នុងអំឡុងសវនាការដេញដោលលើភស្តុតាងឯកសារ ភាគីត្រូវបានផ្តល់ឱកាសឲ្យធ្វើការជំទាស់របស់ខ្លួនទៅនឹងឯកសារនានា ដែលបានដកស្រង់នៅក្នុងជើងទំព័ររបស់ផ្នែកប្រវត្តិបក្សកុម្មុយនីស្តកម្ពុជាក្នុងដីកាដំណោះស្រាយ។ ក្រោយមកទៀត នៅថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២ ភាគីត្រូវបានផ្តល់ឱកាសដាក់ជំទាស់ទៅនឹងឯកសារនានា ដែលបានដកស្រង់នៅក្នុងជើងទំព័រក្នុងកថាខណ្ឌនានារបស់ដីកាដំណោះស្រាយទាក់ទងនឹងប្រព័ន្ធទំនាក់ទំនង និងរចនាសម្ព័ន្ធរដ្ឋបាល និងធាតុផ្សំមួយចំនួននៃតួនាទីរបស់ជនជាប់ចោទ ("សវនាការដេញដោលលើភស្តុតាងឯកសារលើកទីពីរ")។ នៅថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូង ប្រកាសឲ្យដឹងថាខ្លួនមានបំណងដាក់ឯកសារបន្សល់ទុកពីរបបកម្ពុជាប្រជាធិបតេយ្យ ដែលមានក្នុងឧបសម្ព័ន្ធ A1-A10 របស់សហព្រះរាជអាជ្ញា (*សូមមើល* ការកំណត់កាលបរិច្ឆេទលើសេចក្តីសម្រេចលើកទី២ ទៅលើការជំទាស់ទៅនឹងឯកសារនានាដែលភាគីបានស្នើ/ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១២/សាធារណៈ ៤

ឯកសារ ដែលមាននៅក្នុងបញ្ជីឧបសម្ព័ន្ធ A1 ដល់ A5។ អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចលើការជំទាស់ទាំងនេះ ក៏ដូចជាលើការជំទាស់ទៅនឹងឯកសារដែលបានដកស្រង់នៅក្នុងកថាខណ្ឌពាក់ព័ន្ធរបស់ដីកាដំណោះស្រាយ កាលពីថ្ងៃទី ៩ ខែ មេសាឆ្នាំ ២០១២[6]។

4. ការជំទាស់ទៅនឹងឯកសារនៅក្នុងឧបសម្ព័ន្ធ A6-A11 និងA14-20 របស់សហព្រះរាជអាជ្ញា និង ឯកសារមួយចំនួន ស្នើឡើងដោយភាគីផ្សេងទៀត ត្រូវបានលើកឡើងក្នុងសវនាការពីថ្ងៃទី ១២ ដល់ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១២ ("សវនាការដេញដោលលើ ឯកសារភស្តុតាង លើកទីបី")[7]។

## ៣. សារណា

### ៣.១ ឯកសារនៅក្នុងឧបសម្ព័ន្ធ A6-A11 និង A14-A20 របស់សហព្រះរាជអាជ្ញា

5. បន្ថែមពីលើការជំទាស់ជាលាយលក្ខណ៍អក្សររបស់ខ្លួន មេធាវីការពារក្តីគ្រប់ក្រុមទាំងអស់មានឱកាសដាក់ការជំទាស់ដោយផ្ទាល់មាត់ទៅនឹងឯកសារនៅក្នុងឧបសម្ព័ន្ធ A6-A11 និង A14-A20 នៅក្នុង

---

សវនាការផ្ទាល់មាត់លើភស្តុតាងឯកសារ (ថ្ងៃទី ១៦-១៩ ខែ មករា ឆ្នាំ ២០១២) ឯកសារ E159 ថ្ងៃទី ១១ ខែមករា ឆ្នាំ ២០១២ ("ដីកាសម្រេចស្តីពីសវនាការដេញដោលលើភស្តុតាងឯកសារលើកទីមួយ"), កថាខណ្ឌ ៨។

[6] សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងឧបសម្ព័ន្ធ A1-A5 របស់សហព្រះរាជអាជ្ញា និងចំពោះឯកសារដែលបានដកស្រង់នៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយ ដែលពាក់ព័ន្ធនឹងសវនាការដំណាក់កាលពីរដំបូងនៃសំណុំរឿង ០០២/០១ ឯកសារលេខ E185 ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១២ ("សេចក្តីសម្រេចស្តីពីក្របខ័ណ្ឌដាក់ឯកសារ") ជាមួយនឹងឧបសម្ព័ន្ធចំនួន២ (ឯកសារលេខ E185.1 និង E185.2)។

[7] ប្រតិចារិក ថ្ងៃទី ១២-១៥ ខែ មីនា ឆ្នាំ ២០១២ បច្ចុប្បន្នភាពទៅលើអនុស្សរណៈស្តីពីសវនាការដេញដោលលើភស្តុតាងឯកសារនៅដំណាក់កាលបន្ទាប់ (ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី ១២ ដល់ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២) ឯកសារលេខ E172/5 ថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០១២ កថាខណ្ឌ ២។ សវនាការនេះ កំណត់ត្រឹមតែឯកសារ ដែលរហូតមកដល់ពេលនេះ មិនទាន់បានពិភាក្សាក្នុងតុលាការ ឬមិនទាន់បានពិចារណាក្នុងសេចក្តីសម្រេចស្តីពីឯកសារក្នុងក្របខណ្ឌនៅឡើយទេ។ ដោយហេតុថា ឯកសារមួយចំនួននៅក្នុងឧបសម្ព័ន្ធរបស់សហព្រះរាជអាជ្ញា A6-A20 ក៏ត្រូវបានដកស្រង់នៅក្នុងជើងទំព័ររបស់ដីកាដំណោះស្រាយដែរនោះ ការជំទាស់ទៅនឹងឯកសារទាំងនោះ ត្រូវបានពិចារណាក្នុងសេចក្តីសម្រេចឯកសារក្នុងក្របខ័ណ្ឌ (*សូមមើល* ឧបសម្ព័ន្ធ ក ភ្ជាប់នឹងសេចក្តីសម្រេចស្តីពីឯកសារក្នុងក្របខ័ណ្ឌ (ឯកសារលេខ E185.1))។ ការជំទាស់របស់មេធាវីការពារក្តីចំពោះឯកសារក្នុងឧបសម្ព័ន្ធ A12-A13 មិនត្រូវបានពិចារណាក្នុងសវនាការដេញដោលលើភស្តុតាងឯកសារលើកទី៣ ប៉ុន្តែត្រូវបានដោះស្រាយក្នុងសេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារលេខ E96/7 ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ ("សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយសាក្សី")។

សេចក្តីសម្រេចលើកទី២ ទៅលើការជំទាស់ទៅនឹងឯកសារនានាដែលភាគីបានស្នើ/ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១២/សាធារណៈ ៥

gs Rl

សវនាការដេញដោលលើឯកសារភស្តុតាងលើកទីបី[8]។ សារណាដើមរបស់ក្រុមមេធាវីការពារក្តីលើកឡើងពីការជំទាស់ទៅនឹងឯកសារនៅក្នុងឧបសម្ព័ន្ធ A1-A20 របស់សហព្រះរាជអាជ្ញា ហើយការជំទាស់នៅពេលនេះទៅនឹងឯកសារភាគច្រើននៅក្នុងឧបសម្ព័ន្ធ A6-A11 និង A14-A20 មានលក្ខណៈដូចគ្នាទៅនឹងការជំទាស់ ដែលត្រូវបានដោះស្រាយនៅក្នុងសេចក្តីសម្រេចលើក្របខ័ណ្ឌដាក់ឯកសារ។ ក្រុមមេធាវីការពារក្តី ជំទាស់ទៅនឹងការដាក់ឯកសារខ្លះក្នុងចំណោមឯកសារទាំងនេះ ផ្អែកលើមូលដ្ឋានខាងក្រោមនេះ[9]៖

i. ឯកសារភាគច្រើនស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១[10]។

ii. មិនមែនឯកសារទាំងអស់នេះ សុទ្ធតែមានភាពជាប់ទាក់ទងទៅនឹងការបញ្ជាក់ការពិតឡើយ[11]។

iii. សំណៅឯកសារចម្លងមួយចំនួន មិនអាចផ្ទៀងផ្ទាត់ជាមួយឯកសារច្បាប់ដើម[12]។

iv. ដោយសារសហព្រះរាជអាជ្ញាក៏ជាភាគីក្នុងកិច្ចដំណើរការនីតិវិធីដែរ ហើយមិនមែនជាអ្នកដែលចេញពីប្រភពឯករាជ្យ ដូច្នេះឯកសារណាដែលរៀបចំដោយបុគ្គលដែលជាប់ទាក់ទងនឹងការិយាល័យសហព្រះរាជអាជ្ញា ត្រូវធ្វើការវាយតម្លៃដោយប្រុងប្រយ័ត្ន និងទទួលយកតែឯកសារណាដែលអ្នករៀបរៀង ផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ហើយត្រូវដាក់ឲ្យសួរដេញដោលតែប៉ុណ្ណោះ[13]។

---

[8] *សូមមើលផងដែរ* ដីកាកំណត់កាលបរិច្ឆេទសម្រាប់ភាគីធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល (ថ្ងៃទី ១៣-១៦ ខែ កុម្ភៈ ឆ្នាំ ២០១២) ឯកសារលេខ E170 ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ៦ (បញ្ជាក់ថាការកំណត់ពេលវេលាតុលាការសម្រាប់ទទ្បីករណ៍តទល់គ្នាទាក់ទងនឹងប្រភេទជាក់លាក់នៃឯកសារ ត្រូវបានប្រមើលមើលថាជាជម្រើសជំនួសឲ្យការដាក់សារណាជំទាស់ជាលាយលក្ខណ៍អក្សរ)។

[9] ប្រតិចារិក ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ១ និង ៣៥-៣៦, ប្រតិចារិក ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ៤ (ភាសាអង់គ្លេស) (ផ្អែកលើលក្ខណៈវិនិច្ឆ័យដែលមានចែងក្នុងវិធាន ៨៧ (៣) (ក), (គ) និង (ឃ) នៃវិធានផ្ទៃក្នុង)។

[10] ប្រតិចារិក ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ៧២, ប្រតិចារិក ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ៣,៥ និង ១២-១៥, ប្រតិចារិក ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ៣២-៣៣ និង ៣៧ (ភាសាអង់គ្លេស)។

[11] ប្រតិចារិក ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ៣៤ (ភាសាអង់គ្លេស)។

[12] ប្រតិចារិក ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ៦៣-៦៤ និង ៦៧, ប្រតិចារិក ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ៨ (ភាសាអង់គ្លេស)។

[13] ប្រតិចារិក ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ៦៤-៦៦, ៧៨ និង១០៤ (ភាសាអង់គ្លេស)។

v. ឯកសារទាក់ទងនឹងអំពើ ឬការប្រព្រឹត្តិរបស់ជនចាប់ចោទ ឬបញ្ហាគន្លឹះនៅក្នុងរឿងក្តី មិនអាចទទួលយក ដោយគ្មានការសួរដេញដោលចំពោះសាក្សីដែលជាប់ទាក់ទងឡើយ[14]។

vi. ឯកសារដូចជារបាយការណ៍កំណត់អត្តសញ្ញាណទីកន្លែង ផែនទី រូបថត ខ្សែអាត់សំឡេង វីដេអូ សេចក្តីរាយការណ៍ព័ត៌មានអន្តរជាតិ អត្ថបទសិក្សាស្រាវជ្រាវ របាយការណ៍វិភាគ សៀវភៅ របាយការណ៍ស្តីពីការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស អាចទទួលយកបាន បើសិនជាឯកសារទាំងនោះមានយថាភាព មានភាពជាប់ទាក់ទង ឬអាចជឿទុកចិត្តបាន និងបើសិនជាអ្នករៀបរៀង អ្នកផលិត ឬសាក្សីដែលជាប់ទាក់ទងផ្សេងទៀត ផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ[15]។

vii. ឯកសារមួយចំនួន អាចជាឯកសារដែលទទួលបានពីការធ្វើទារុណកម្ម ហេតុដូច្នេះមិនអាចទទួលយកឡើយ អនុលោមតាមយុត្តិសាស្ត្រដែលពាក់ព័ន្ធរបស់ អ.វ.ត.ក[16]។

viii. មិនមែនឯកសារទាំងអស់ សុទ្ធតែមានជាភាសាផ្លូវការទាំងបីរបស់ អ.វ.ត.ក ទេ[17]។

ix. គប្បីមិនទទួលយកប្រតិចារិកនៃសវនាការក្នុងសំណុំរឿង ០០១ ឡើយ ហើយសាក្សីដែលបានផ្តល់សក្ខីកម្មក្នុងសំណុំរឿង០០១ ដែលសក្ខីកម្មរបស់ពួកគាត់ មានភាពចាំបាច់សម្រាប់សំណុំរឿង០០២/០១ គប្បីត្រូវបានកោះអញ្ជើញឱ្យផ្តល់សក្ខីកម្មឡើងវិញ[18]។

---

[14] ប្រតិចារិក ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ៦៨, ៧៩-៨០, ៨៣ និង ៨៧, ប្រតិចារិក ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ៥ និង២០-២១ (ភាសាអង់គ្លេស)។

[15] ប្រតិចារិក ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ៩៦-១០៥, ប្រតិចារិក ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ៨, ១៣, ១៥-១៧, និង ២០ (ភាសាអង់គ្លេស)។

[16] ប្រតិចារិក ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ៧៤, ៨៤, ៩២ និង៩៤, ប្រតិចារិក ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ១០ (ភាសាអង់គ្លេស)។

[17] ប្រតិចារិក ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ៨៨, ៩២ និង ១០១, ប្រតិចារិក ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ១៦ និង១៩ (ភាសាអង់គ្លេស)។

[18] ប្រតិចារិក ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ៩៤ និង ៩៦, ប្រតិចារិក ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ១១ (ភាសាអង់គ្លេស)។

x. ដំណើររក្សាឯកសារភស្តុតាងដែលមានប្រភពពីមជ្ឈមណ្ឌលឯកសារកម្ពុជា ("DC-Cam") អាចមានបញ្ហាចោទ ហើយសក្ខីកម្មដែលផ្តល់ដោយបុគ្គលិក DC-Cam បង្ហាញឲ្យដឹងថា ឯកសារទាំងនេះ អាចមិនមានភាពជឿទុកចិត្តបាន[19] និង

xi. គប្បីសម្រេចមិនទទួលយកឯកសារទាក់ទងនឹងជនជាប់ចោទ អៀង ធីរិទ្ធ ឬធ្វើការសម្រេចទទួលយកដោយប្រុងប្រយ័ត្ន បន្ទាប់ពីគាត់ត្រូវបានបំបែកចេញពីកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០១[20]។

6. ជាការឆ្លើយតប សហព្រះរាជអាជ្ញាទទួលស្គាល់ថា ដើម្បីដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារទាំងនោះ *ជាដំបូង* ត្រូវស្របតាមបទដ្ឋាននៃភាពអាចជឿទុកចិត្តបាន ភាពជាប់ទាក់ទង និងយថាភាព ដូចមានចែងក្នុងវិធាន ៨៧ (៣) នៃវិធានផ្ទៃក្នុង[21]។ ទោះជាយ៉ាងនេះក្តី គប្បីវាយតម្លៃលើឯកសារទាំងស្រុង, ថ្លឹងថ្លែងអំពីតម្លៃរបស់ឯកសារទាំងនោះដែលអាចបញ្ជាក់អង្គហេតុបាន និងវាយតម្លៃអំពីចរិតលក្ខណៈខាងក្នុង និងខាងក្រៅនៃភាពជឿទុកចិត្តបានរបស់ឯកសារទាំងនោះ[22]។ ការជំទាស់ជាច្រើនរបស់ក្រុមមេធាវីការពារក្តី លើកឡើងអំពីតម្លៃនៃភស្តុតាង និងទម្ងន់នៃភស្តុតាងជាជាងអំពីភាពអាចទទួលយកបាននៃភស្តុតាង[23]។ ប្រភពដើម និងដំណើរការរក្សាឯកសារភស្តុតាងទាំងនេះ មិនមានភាពសង្ស័យទេ ដោយហេតុថា ឯកសារទាំងនេះមានប្រភពអាចជឿទុកចិត្តបាន ដូច្នេះហើយ ឯកសារទាំងនេះមានយថាភាព និងអាចជឿទុកចិត្តបាន[24]។ ឯកសារបន្ទាប់បន្សំទាក់ទងនឹងអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទ (ដូចជាឯកសារ ឬសៀវភៅដែលនៅបន្សល់ទុកពីរបបកម្ពុជាប្រជាធិបតេយ្យ) អាចទទួលយកបាន ក្រោមក្របខ័ណ្ឌច្បាប់ អ.វ.ត.ក ដោយមិនចាំបាច់កោះអញ្ជើញអ្នកនិពន្ធម្នាក់ៗឲ្យមកផ្តល់សក្ខីកម្មឡើយ ហើយអង្គជំនុំជម្រះសាលាដំបូង មានតួនាទីថ្លឹងថ្លែងឯកសារ

---

[19] ប្រតិចារិក ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ៨-៩ និង ប្រតិចារិក ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ៤០ (ភាសាអង់គ្លេស)។

[20] ប្រតិចារិក ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ៨៤-៨៥, ប្រតិចារិក ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ៣ (ភាសាអង់គ្លេស)។

[21] ប្រតិចារិក ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ២៨-២៩ (ភាសាអង់គ្លេស)។

[22] ប្រតិចារិក ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ៦៩-៧០ និង ប្រតិចារិក ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ៩ (ភាសាអង់គ្លេស)។

[23] ប្រតិចារិក ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ៣០ និង ៣២ (ភាសាអង់គ្លេស)។

[24] ប្រតិចារិក ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ៤៣ (ភាសាអង់គ្លេស)។



ᨀ Rl

នីមួយៗឱ្យបានសមស្របក្នុងការវាយតម្លៃភស្តុតាងទាំងអស់[25]។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក៏មានមតិស្របគ្នានឹងសហព្រះរាជអាជ្ញាដែរ[26]។

## ៣.២ ឯកសារស្នើឡើងដោយភាគីផ្សេងទៀត

7. ក្រុមមេធាវីការពារក្តីយល់ឃើញថា មានតែឯកសារមួយប៉ុណ្ណោះដែលស្នើឡើងដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានភាពជាប់ទាក់ទងនឹងសំណុំរឿង០០២/០១[27]។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីជំទាស់ថា ឯកសារទាំងអស់ដែលបានស្នើឡើង មានភាពជាប់ទាក់ទង ប៉ុន្តែយល់ស្របថា មិនមែនឯកសារទាំងអស់ដែលខ្លួនបានស្នើ សុទ្ធមានគ្រប់ភាសាផ្លូវការរបស់ អ.វ.ត.ក នោះទេ[28]។ ទោះបីជាយ៉ាងណា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីជំទាស់ថា មិនគួរប្រកាសមិនទទួលយកឯកសារណាមួយក្នុងដំណាក់កាលនេះ ដោយសំអាងថាឯកសារនោះមិនទាន់មានគ្រប់ភាសាផ្លូវការរបស់ អ.វ.ត.ក ឬដោយសារការបកប្រែភាសាឡើយ[29]។

8. សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនជំទាស់នឹងឯកសារដែលស្នើឡើងដោយក្រុមមេធាវីការពារក្តីទេ[30]។ ក្រុមមេធាវីការពារក្តី អៀង សារី ជំទាស់លើ ឯកសារមួយដែលស្នើឡើងដោយ ខៀវ សំផន ទាក់ទងនឹងជនជាប់ចោទ អៀង ធីរិទ្ធ ដោយហេតុថា អៀង ធីរិទ្ធ លែងជាភាគីពាក់ព័ន្ធនៅក្នុងសំណុំរឿង០០២/០១ ទៀតហើយ[31]។

---

[25] ប្រតិចារិក ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ៦៩-៧០ (ភាសាអង់គ្លេស)។

[26] ប្រតិចារិក ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ១០៧-១០៨ (ភាសាអង់គ្លេស)។

[27] ប្រតិចារិក ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ៧១ និង ១១០, ប្រតិចារិក ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ២១។

[28] ប្រតិចារិក ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ១០៨ (ភាសាអង់គ្លេស)។

[29] ប្រតិចារិក ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ១០២ (ភាសាអង់គ្លេស)។

[30] ប្រតិចារិក ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ២៣-២៤ និង១០៣-១០៤ (ភាសាអង់គ្លេស) (កត់សម្គាល់ថាឯកសារខ្លះនៅក្នុងឧបសម្ព័ន្ធរបស់ខ្លួន ក៏ត្រូវបានស្នើដោយមេធាវីការពារក្តី ខៀវ សំផនដែរ)។

[31] ប្រតិចារិក ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ១១០ (ភាសាអង់គ្លេស)។

## ៤. សំអាងហេតុ

### ៤.១ សេចក្តីផ្តើម

9. នៅក្នុងសេចក្តីសម្រេចស្តីពីក្របខ័ណ្ឌដាក់ឯកសារ អង្គជំនុំជម្រះបានលើកឡើងនូវគោលការណ៍ទូទៅ ដែលកំណត់ពីភាពអាចទទួលយកបាននៃឯកសារនៅក្នុងក្របខ័ណ្ឌច្បាប់នៅ អ.វ.ត.ក[32] ដូចខាងក្រោម៖

ក. ឯកសារទាំងអស់ដែលបានយោងនៅក្នុងផ្នែកទាំងប៉ុន្មាននៃដីកាដំណោះស្រាយ ដែលពាក់ព័ន្ធនឹងវគ្គនីមួយៗ ដែលត្រូវធ្វើសវនាការក្នុងសំណុំរឿង ០០២/០១ ត្រូវបានសន្មតថាមានភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បាន (រួមទាំងយថាភាព)[33]។

ខ. ឯកសារពីសម័យកម្ពុជាប្រជាធិបតេយ្យ ដែលមានប្រភពចេញពីមជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវបានទទួលការសន្មតបឋម ដែលអាចជំទាស់បាននូវភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បាន (រួមទាំងយថាភាព)។ ផ្អែកលើសក្ខីកម្មរបស់ប្រធាន និងអនុប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជា អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា វិធីសាស្ត្រដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រើប្រាស់ក្នុងការទទួលបានឯកសារ ការធ្វើបណ្ណសារ និងការរក្សាទុកឯកសារមានភាពអាចឱ្យជឿជាក់បាន និងពុំមានមូលដ្ឋានណាមួយដើម្បីសន្និដ្ឋានថា

---

[32] *សូមមើលផងដែរ* ដីកាកំណត់កាលបរិច្ឆេទសវនាការលើឯកសារលើកទី១។ ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងផ្នែកខ្លះនៃឯកសារ E114, E114/1, E131/1/9, E131/6, E136 និង E158, ឯកសារលេខ E162, ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ ("សេចក្តីសង្ខេបសេចក្តីសម្រេចផ្ទាល់មាត់"); សេចក្តីសម្រេចលើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួររបស់ នួន ជា ដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងភាពមិនស៊ីសង្វាក់គ្នានៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងជាសំឡេងនៃការស្តាប់ចម្លើយសាក្សីរបស់ ក.ស.ច.ស, ឯកសារលេខ E142/3, ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ ("សេចក្តីសម្រេចលើខ្សែអាត់សំឡេង"); សេចក្តីសម្រេចលើឯកសារថ្មី និងចម្លើយសាក្សី។

[33] សេចក្តីសម្រេចលើក្របខ័ណ្ឌដាក់ឯកសារ, កថាខណ្ឌ ២០; *សូមមើលផងដែរ* សេចក្តីសង្ខេបសេចក្តីសម្រេចផ្ទាល់មាត់, កថាខណ្ឌ ៣ និង ប្រតិចារឹក, ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១២, ទំព័រ ៨៥-៨៨ (ភាសាអង់គ្លេស)។

ឯកសារនានាដែលមានប្រភពចេញពីមជ្ឈមណ្ឌលឯកសារកម្ពុជាអាចត្រូវបានក្លែង បន្លំ ឬក្លែងក្លាយឡើយ[34]។

គ. អង្គជំនុំជម្រះក៏បានបដិសេធពុំប្រើប្រាស់ការសន្មតអំពីភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បាន (រួមទាំងយថាភាព) សម្រាប់ឯកសារទាំងអស់ដែលត្រូវបានដាក់ចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០១ ឡើយ ដោយសំអាងថា មិនមែនឯកសារទាំងអស់នេះ សុទ្ធតែជាប់ពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ នោះទេ។ ទោះបីជាដូច្នេះក្តី ភាពអាចជឿជាក់បានដែលត្រូវបានផ្តល់ទៅឯកសារទាំងនេះក្នុងសំណុំរឿង ០០១ គឺជាកត្តាមួយដែលអង្គជំនុំជម្រះសាលាដំបូងត្រូវពិចារណាក្នុងការសម្រេចថា តើលក្ខខណ្ឌតម្រូវនៃវិធាន ៨៧ នៃវិធានផ្ទៃក្នុងត្រូវបានបំពេញដែរ ឬទេ[35]។

ឃ. ក្នុងចំណោមចំណុចផ្សេងទៀត បញ្ហានានាពាក់ព័ន្ធនឹងភាពអាចអានបាននៃសំណៅថតចម្លងនៃឯកសារ ឬចំណុចមិនស្របគ្នារវាងកំណត់ហេតុជាខ្សែអាត់សំឡេង និងចម្លើយជាលាយលក្ខណ៍អក្សរ ដែលសង្ខេបឯកសារនោះ គឺជាបញ្ហាពាក់ព័ន្ធនឹងតម្លៃ និងទម្ងន់នៃភស្តុតាងដែលត្រូវផ្តល់ទៅឱ្យឯកសារទាំងនោះ ជាជាងភាពអាចទទួលយកបាននៃឯកសារនោះដោយអនុលោមតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង[36]។

ង. ពុំមានលក្ខខណ្ឌតម្រូវណាមួយនៅក្នុងក្របខ័ណ្ឌច្បាប់នៅ អ.វ.ត.ក ដែលថា ឯកសារដែលដាក់នៅចំពោះមុខអង្គជំនុំជម្រះ ត្រូវតែជាឯកសារដែលមានទំនាក់ទំនងជាមួយនឹងសក្ខីកម្មរបស់សាក្សី អ្នកជំនាញ ឬដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។ ទន្ទឹមនឹងពេលដែល

---

[34] សេចក្តីសម្រេចលើក្របខ័ណ្ឌនៃដាក់ឯកសារ, កថាខណ្ឌ ២៨។ នៅក្នុងចំណោមឯកសារនានាដែលបានបញ្ចូលក្នុងឧបសម្ព័ន្ធ ១-២០ សហព្រះរាជអាជ្ញាបានកំណត់ថាឯកសារចំនួន ២.៣៨៤ មានប្រភពមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា (*សូមមើល* ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់មេធាវីការពារក្តី នួន ជា ស្នើសុំបញ្ជីឯកសារដែលបានផ្តល់ជូនដោយមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) ដែលមាននៅក្នុងបញ្ជីឯកសារដំបូងរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៨០(៣) ជាមួយនឹងឧបសម្ព័ន្ធ ក និង ខ សម្ងាត់, ឯកសារលេខ E161, ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១២)។

[35] សេចក្តីសម្រេចលើក្របខ័ណ្ឌដាក់ឯកសារ, កថាខណ្ឌ ៣៤។ *សូមមើលផងដែរ* ប្រតិចារិក ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១២ ទំព័រ៦៥-៦៦ (ភាសាអង់គ្លេស) (សូមកត់សម្គាល់ថា អង្គជំនុំជម្រះបានសម្រេចដាក់នៅចំពោះមុខខ្លួនរួចហើយ នូវចម្លើយសាក្សីជាលាយលក្ខណ៍អក្សរ របស់កាំង ហ្កេកអ៊ាវ ដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ហេតុដូច្នេះ អង្គជំនុំជម្រះបដិសេធការជំទាស់របស់មេធាវីការពារក្តី)។

[36] សេចក្តីសម្រេចលើក្របខ័ណ្ឌដាក់ឯកសារ, កថាខណ្ឌ ២១ និង ៣០។



ɟ+ Rl

ប្រភពឯកសារនានា ដូចជា សៀវភៅ របាយការណ៍វិភាគ ភាពយន្តឯកសារ ឬអត្ថបទសារព័ត៌មាន អាចត្រូវបានទទួលយកនោះ អង្គជំនុំជម្រះក៏ត្រូវពិចារណាអំពីតម្លៃ និងទម្ងន់នៃភស្តុតាងស្របទៅតាមប្រភពនៃឯកសារទាំងនេះផងដែរ តាមពេលវេលាដ៏សមស្រប[37]។

ច. ការជំទាស់ ដែលពុំបានលើកឡើងនូវមូលដ្ឋានជាក់លាក់គ្រប់គ្រាន់នៃភាពមិនអាចទទួលយកបាននៃឯកសារជាក់លាក់ ឬប្រភេទនៃឯកសារនានានោះ នឹងត្រូវបានបដិសេធ[38]។

10. គោលការណ៍ពាក់ព័ន្ធនានាដែលកំណត់ពីភាពអាចទទួលយកបាន និងលក្ខណៈវិនិច្ឆ័យសម្រាប់វាយតម្លៃទៅលើឯកសារថ្មីៗ និងកំណត់ហេតុជាលាយលក្ខណ៍អក្សរដែលភាគីបានស្នើ ដោយពុំមានការផ្ដល់សក្ខីកម្មពីអ្នករៀបរៀងនៃឯកសារទាំងនោះ រួមទាំងបែបបទនៃការសួរដេញដោលចំពោះឯកសារភស្តុតាងនេះត្រូវបានកំណត់នៅក្នុងសេចក្ដីសម្រេចបន្តបន្ទាប់ទៀតរបស់អង្គជំនុំជម្រះ និងនៅក្នុងអនុស្សរណៈនៃកិច្ចប្រជុំរៀបចំសវនាការ[39]។

## ៤.២ ការជំទាស់ទៅនឹងឯកសារនានាដែលមាននៅក្នុងឧបសម្ព័ន្ធ A6-A11 និង A14-A20 របស់សហព្រះរាជអាជ្ញា

11. អនុលោមតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង មានតែឯកសារដែលមានភាពពាក់ព័ន្ធ អាចជឿជាក់បាន និងមានយថាភាព តាមការវិភាគបឋមទេ ទើបអាចដាក់នៅចំពោះមុខអង្គជំនុំជម្រះបាន។ អង្គជំនុំជម្រះបានពិនិត្យឡើងវិញទៅលើឯកសារនីមួយៗដែលមាននៅក្នុងឧបសម្ព័ន្ធ A6-A11 និង A14-A20 និងបានពិចារណាចំពោះការជំទាស់នានាទៅលើឯកសារទាំងនោះ ដែលភាគីបានលើក

---

37 សេចក្ដីសម្រេចលើក្របខ័ណ្ឌដាក់ឯកសារ, កថាខណ្ឌ ២១ និង ៣១។

38 សេចក្ដីសម្រេចលើក្របខ័ណ្ឌដាក់ឯកសារ, កថាខណ្ឌ ២៣; *សូមមើលផងដែរ* ដីកាកំណត់កាលបរិច្ឆេទសវនាការលើឯកសារលើកទី១, កថាខណ្ឌ ២។

39 *សូមមើលឧទាហរណ៍* សេចក្ដីសម្រេចលើឯកសារថ្មី; សេចក្ដីសម្រេចលើចម្លើយសាក្សី, កថាខណ្ឌ ២០-២៥ និង៣០-៣១ (*សូមមើលផងដែរ* សវនាការដេញដោលលើឯកសារនាពេលខាងមុខ និងចម្លើយតបទៅនឹងអនុស្សរណៈរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង ស្នើសុំកំណត់អត្តសញ្ញាណនៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីសម្រាប់ប្រើប្រាស់នៅសវនាការ (ឯកសារ E208/4) និងសំណើរបស់មេធាវីការពារក្ដីជនជាប់ចោទ អៀង សារី ស្នើសុំកែតម្រូវបញ្ជីភស្តុតាងគាំទ្រ (ឯកសារ E223), ឯកសារលេខ E223/2, ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២។

ឡើង ពាក់ព័ន្ធនឹងលក្ខណៈវិនិច្ឆ័យនៅក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង និងយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង។

12. មេធាវីការពារក្តីបានជំទាស់ទៅនឹងឯកសារមួយចំនួន ដោយគ្រាន់តែអះអាងដោយពុំមានការពន្យល់ថា ឯកសារទាំងនោះមិនពាក់ព័ន្ធទេ។ ទោះបីការជំទាស់ពុំមានភាពជាក់លាក់ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការមិនទទួលយកឯកសារជាក់លាក់មួយចំនួន ឬប្រភេទឯកសារនានា ដែលជាទូទៅអង្គជំនុំជម្រះត្រូវបដិសេធក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងបានពិនិត្យឡើងវិញទៅលើឯកសារទាំងអស់ដែលត្រូវបានជំទាស់ឈរលើមូលដ្ឋានទាំងនេះដែរ។ អង្គជំនុំជម្រះសន្និដ្ឋានថា ឯកសារទាំងអស់ [លើកលែងតែឯកសារលេខ D29 (សំណើដាក់ដោយសហព្រះរាជអាជ្ញា) ស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ និងពាក់ព័ន្ធនឹងការស្វែងរកការពិត ហេតុនេះអង្គជំនុំជម្រះបានសម្រេចទទួលយកឯកសារទាំងនេះជាភស្តុតាង។ ដូច្នេះ ការជំទាស់របស់មេធាវីការពារក្តីដែលបានរៀបរាប់នៅក្នុងកថាខណ្ឌ ៥(i) និង (ii) (ខាងលើ) ត្រូវបានបដិសេធចោល។

13. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ការជំទាស់មួយចំនួនមានភាពពាក់ព័ន្ធនឹងទម្ងន់ជាភស្តុតាងរបស់ឯកសារមួយចំនួន មិនមែនជំទាស់លើបញ្ហាថា តើឯកសារទាំងនោះអាចដាក់នៅចំពោះមុខអង្គជំនុំជម្រះអនុលោមតាមវិធាន ៨៧ នៃវិធានផ្ទៃក្នុងនោះទេ។ សំណួរនានាដែលពាក់ព័ន្ធនឹងតម្លៃ និងទម្ងន់នៃភស្តុតាងដែលត្រូវផ្តល់ទៅឱ្យឯកសារ ពុំពាក់ព័ន្ធទៅនឹងការវាយតម្លៃពីភាពសមស្របរបស់ឯកសារទាំងនោះទៅនឹងលក្ខណៈវិនិច្ឆ័យស្របតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុងទេ។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះត្រូវពិចារណាទៅលើតម្លៃ និងទម្ងន់នៃភស្តុតាងដែលត្រូវផ្តល់ទៅឱ្យឯកសារក្នុងពេលវាយតម្លៃចំពោះភស្តុតាងទាំងអស់ដែលពាក់ព័ន្ធនឹងសាលក្រម។ ហេតុនេះ អង្គជំនុំជម្រះបដិសេធការជំទាស់នានារបស់មេធាវីការពារក្តី ដែលមានរៀបរាប់ក្នុងកថាខណ្ឌ ៥ (iii)។

14. អង្គជំនុំជម្រះធ្វើការសន្និដ្ឋានបន្ថែមទៀតថា ការជំទាស់ទៅនឹងឯកសារនានាដែលបានរៀបចំដោយមន្ត្រីដែលមានទំនាក់ទំនងជាមួយនឹងការិយាល័យសហព្រះរាជអាជ្ញា ជាបញ្ហាដែលពាក់ព័ន្ធនឹងទម្ងន់ដែលត្រូវផ្តល់ទៅឱ្យឯកសារ ជាជាងភាពទទួលយកបាននៃឯកសារទាំងនោះ អនុលោមតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះទទួលស្គាល់ថា ឯកសារមួយចំនួនដែលបានដាក់



ar RA

ចំពោះមុខអង្គជំនុំជម្រះ ត្រូវបានរៀបចំដោយបុគ្គលដែលភាគីមានបំណងស្នើសុំមកផ្តល់សក្ខីកម្ម ក្នុងនាមជាអ្នកជំនាញ នៅចំពោះមុខអង្គជំនុំជម្រះ និង ការសម្រេចចុងក្រោយថា តើបុគ្គលទាំងនេះ នឹងត្រូវមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ឬយ៉ាងណានោះ កំពុងស្ថិតក្នុងការពិចារណានៅឡើយ។ ទោះបីជាអង្គជំនុំជម្រះសម្រេចថា ឯកសារទាំងនេះពាក់ព័ន្ធទៅនឹងសណុំរឿង ០០២/០១ អង្គជំនុំជម្រះក៏យល់ស្របថា ការពុំមានលទ្ធភាពសាកសួរដល់អ្នករៀបរៀងឯកសារមួយចំនួននោះ បានធ្វើឱ្យប៉ះពាល់ដល់តម្លៃជាភស្តុតាងរបស់វា។ ហេតុដូច្នេះ អង្គជំនុំជម្រះបដិសេធការជំទាស់របស់មេធាវីការពារក្តី ដែលមាននៅក្នុងកថាខណ្ឌ៥(iv)។

15. នៅក្នុងសេចក្តីសម្រេចមុន អង្គជំនុំជម្រះរកឃើញឯកសារបួន ដែលពាក់ព័ន្ធទៅនឹងជនជាប់ចោទ អៀង ធីរិទ្ធ ដែលជាឯកសារលែងពាក់ព័ន្ធនឹងសំណុំរឿង០០២/០១[40] ទៀតហើយ។ អង្គជំនុំជម្រះកត់សម្គាល់ថា ទោះបីមានឯកសារមួយចំនួនដែលមានរៀបរាប់ក្នុងឧបសម្ព័ន្ធ A6-A11 និង A14-A20 ពាក់ព័ន្ធនឹងជនជាប់ចោទ អៀង ធីរិទ្ធ ក៏ដោយ ក៏មានឯកសារមួយចំនួន ក្នុងចំណោមឯកសារទាំងនេះមានភាពពាក់ព័ន្ធនឹងជនជាប់ចោទ ឬបញ្ហាដទៃទៀត ដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ ដែរ។ លើកលែងតែឯកសារចំនួនប្រាំមួយ អង្គជំនុំជម្រះក៏បានធ្វើការសម្រេចថា ឯកសារទាំងនេះ ពាក់ព័ន្ធទៅនឹងសណុំរឿង០០២/០១ ហេតុនេះអង្គជំនុំជម្រះបដិសេធការជំទាស់ដែលបានលើកឡើងប្រឆាំងនឹងឯកសារទាំងនោះក្នុងកថាខណ្ឌ ៥(xi)។

16. ទាក់ទងនឹងឯកសារបកប្រែជាភាសាផ្លូវការទាំងអស់នៅ អ.វ.ត.ក កន្លងមក អង្គជំនុំជម្រះបានបញ្ជាក់ថា ភាគីនានាស្នើសុំបង្ហាញឯកសារនៅពេលសវនាការ ត្រូវធានាឱ្យទាន់ពេលនូវឯកសារបកប្រែជាភាសាផ្លូវការបីភាសា[41]។ អង្គជំនុំជម្រះសាលាដំបូងផ្តល់ការអនុគ្រោះខ្លះ នៅពេលភាគីមិនអាចអនុវត្តដូច្នោះបាន ដោយសារទំហំការងាររបស់អង្គភាពបកប្រែភាសា។ ទោះជាយ៉ាងនេះក្តី ថ្មីៗនេះបន្ទាប់ពីបានពិភាក្សាជាមួយអង្គភាពបកប្រែភាសា អង្គជំនុំជម្រះសាលាដំបូង បានណែនាំឱ្យភាគីធ្វើការកែសម្រួលទំហំឯកសារដែលខ្លួនមានបំណងដាក់ជាភស្តុតាង ហើយអាចដាក់ឯកសារជាភាសាផ្លូវការទាំងអស់នៅ អ.វ.ត.ក ត្រឹមថ្ងៃ ច័ន្ទ ទី ០៤ ខែ មីនា ឆ្នាំ ២០១៣[42]។

---

[40] សេចក្តីសម្រេចលើឯកសារថ្មី, កថាខណ្ឌ ២៧។

[41] សេចក្តីសម្រេចលើក្របខ័ណ្ឌដាក់ឯកសារ, កថាខណ្ឌ ២១។

[42] សវនាការដេញដោលលើឯកសារនាពេលខាងមុខ និងចម្លើយតបទៅនឹងអនុស្សរណៈរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង ស្នើសុំកំណត់អត្តសញ្ញាណនៃពាក្យសុំតាំងខ្លួនជាដើម សេចក្តីសម្រេចលើកទី២ ទៅលើការជំទាស់ទៅនឹងឯកសារនានាដែលភាគីបានស្នើ/ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១២/សាធារណៈ:១៤

អង្គជំនុំជម្រះសាលាដំបូង ច្រានចោលការជំទាស់ដែលបានលើកឡើងក្នុងកថាខណ្ឌ 5(viii) ប៉ុន្តែ ណែនាំដល់ភាគីថា ឯកសារដែលមិនមានការបកប្រែត្រឹមកាលបរិច្ឆេទនេះ មិនត្រូវចាត់ទុកថាជា ឯកសារដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះឡើយ។

17. ចុងក្រោយ អង្គជំនុំជម្រះបដិសេធការជំទាស់នានាដែលមានក្នុងកថាខណ្ឌ ៥(v), (vi), (vii), (ix) និង (x) ទៅតាមសំអាងហេតុដូចគ្នាទាំងស្រុងទៅនឹងការជំទាស់នានាដែលពាក់ព័ន្ធទៅនឹងអ្វីដែល អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចរួចមកហើយ[43]។

18. បន្ទាប់ពីបានពិនិត្យទៅលើឯកសារទាំងអស់ដែលមានក្នុងឧបសម្ព័ន្ធ A6-A11 និង A14-A20 អង្គជំនុំជម្រះសន្និដ្ឋានថា ឯកសារទាំងអស់នេះ មានភាពពាក់ព័ន្ធ និងអាចជឿជាក់បានតាមការ វិភាគ *បឋម* (រួមទាំងយថាភាព) ហើយឯកសារទាំងនោះស្របទៅនឹងលក្ខណៈវិនិច្ឆ័យនៃភាពអាច ទទួលយកបានដែលមានរៀបរាប់ក្នុងវិធាន ៨៧ នៃវិធានផ្ទៃក្នុង លើកលែងតែឯកសារចំនួន ប្រាំពីរ។ ហេតុនេះ អង្គជំនុំជម្រះសម្រេចចុះលេខជាប្រភេទឯកសារ E3 និងដាក់នៅចំពោះមុខ អង្គជំនុំជម្រះ[44]។

19. ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះនឹងពិចារណាទៅលើការជំទាស់ទាំងអស់ដែលបានលើកឡើង នៅ ក្នុងសវនាការចំពោះឯកសារទាំងនេះ នៅពេលថ្លឹងថ្លែងពីតម្លៃជាភស្តុតាងដែលផ្តល់ទៅឲ្យឯកសារ នីមួយៗពាក់ព័ន្ធនឹងសាលក្រម។

---

បណ្តឹងរដ្ឋប្បវេណីសម្រាប់ប្រើប្រាស់នៅសវនាការ (ឯកសារ E208/4) និងសំណើរបស់មេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន ស្នើសុំកែតម្រូវបញ្ជីភស្តុតាងគាំទ្រ (ឯកសារ E223), ឯកសារលេខ E223/2, ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (“អនុស្សរណៈស្តីពីការដេញដោលលើឯកសារនាពេលខាងមុខ”), កថាខណ្ឌ ៩, ១៣។

[43] សេចក្តីសម្រេចលើក្របខ័ណ្ឌដាក់ឯកសារ, កថាខណ្ឌ ២១, ២៨-៣១; (ដែលពាក់ព័ន្ធនឹងចំណុចផ្សេង គឺ ភាពអាចទទួលយក បាននៃសំណៅចម្លងឯកសារ និងភស្តុតាង ដូចជា របាយការណ៍វិភាគ សៀវភៅ ភាពយន្តឯកសារ អត្ថបទសារព័ត៌មាន និង ការប្រើប្រាស់ដែលមានដែនកំណត់មួយចំនួនចំពោះឯកសារដែលទទួលបានដោយការធ្វើទារុណកម្ម) សេចក្តីសម្រេចលើចម្លើយ សាក្សី, កថាខណ្ឌ ២០-២៥, ៣០-៣១ និង៣៤-៣៥ (ពាក់ព័ន្ធនឹងភាពអាចទទួលយកបាននៃប្រតិចារឹកពីសវនាការផ្សេងៗនូវ ចម្លើយសាក្សីជាលាយលក្ខណ៍អក្សរ ដែលជាភស្តុតាងនៃសកម្មភាព និងទង្វើរបស់ជនជាប់ចោទ)។

[44] *សូមមើល* សេចក្តីសម្រេចលើឯកសារថ្មី, កថាខណ្ឌ ១៨។

### ៤.៣ ការជំទាស់នានាដែលពាក់ព័ន្ធនឹងឯកសារដែលភាគីដទៃបានស្នើ

20. ដោយសារពុំមានការជំទាស់ទៅនឹងឯកសារដែលបានស្នើសុំដោយក្រុមមេធាវីការពារក្តី និងបន្ទាប់ពីអង្គជំនុំជម្រះបានពិនិត្យឡើងវិញរួចរាល់ហើយនោះ អង្គជំនុំជម្រះបានសម្រេចថា ឯកសារទាំងនេះឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង ហើយត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ។ អៀង សារី បានជំទាស់ទៅនឹងឯកសារមួយដែលបានស្នើដោយ ខៀវ សំផន ដោយសំអាងថា ឯកសារនោះពាក់ព័ន្ធនឹង អៀង ធីរិទ្ធ[45]។ អង្គជំនុំជម្រះបានពិចារណាឃើញថា ឯកសារនេះក៏មានព័ត៌មានដែលពាក់ព័ន្ធនឹងវិសាលភាពនៃសំណុំរឿង ០០២/០១ ដែរ ហេតុនេះអង្គជំនុំជម្រះបានសម្រេចដាក់ឯកសារនេះនៅចំពោះមុខអង្គជំនុំជម្រះ។

21. ពាក់ព័ន្ធនឹងការជំទាស់របស់មេធាវីការពារក្តីទៅលើឯកសារនានា ដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានស្នើវិញ អង្គជំនុំជម្រះពុំយល់ស្របថា ឯកសារទាំងនេះមិនពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ នោះទេ។ ហេតុនេះ អង្គជំនុំជម្រះសូមបដិសេធការជំទាស់ទាំងនេះ និងសម្រេចដាក់ឯកសារទាំងនេះនៅចំពោះមុខអង្គជំនុំជម្រះ។

### ៤.៤ សេចក្តីសន្និដ្ឋាន

22. រាល់ឯកសារទាំងអស់ដែលអង្គជំនុំជម្រះយកមកពិចារណាក្នុងសេចក្តីសម្រេចនេះ អង្គជំនុំជម្រះសម្រេចមិនដាក់បញ្ចូលឯកសារចំនួនប្រាំពីរនៅចំពោះមុខខ្លួនទេ។ អង្គជំនុំជម្រះបានសម្រេចថា ឯកសារទាំងប្រាំពីរ នេះពុំពាក់ព័ន្ធនឹងសវនាការក្នុងសំណុំរឿង ០០២/០១ ទេ។ អង្គជំនុំជម្រះបានពន្យាសេចក្តីសម្រេចរបស់ខ្លួនទៅលើឯកសារចំនួនជាង ៤០០ ដែលមាននៅក្នុងបញ្ជីឧបសម្ព័ន្ធ ២១ របស់សហព្រះរាជអាជ្ញា ស្របតាមសេចក្តីសម្រេចលើឯកសារថ្មីៗ។ ការលើកអំណះអំណាងតទល់គ្នាពាក់ព័ន្ធនឹងឯកសារទាំងនេះនឹងត្រូវកំណត់កាលបរិច្ឆេទធ្វើក្នុងពេលដ៏ខ្លីខាងមុខ និងសេចក្តីសម្រេចមួយពាក់ព័ន្ធនឹងឯកសារទាំងនោះនឹងត្រូវចេញក្នុងពេលវេលាសមស្រប[46]។

---

[45] ប្រតិចារឹក, ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២, ទំព័រ ១១០ (ភាសាអង់គ្លេស) ដោយយោងទៅដល់ឧបសម្ព័ន្ធ ក៖ បទសម្ភាសន៍របស់ អៀង ធីរិទ្ធ ដោយអ្នកស្រី Elizabeth BECKER, ឯកសារលេខ D108/5.1។

[46] អនុស្សរណៈស្តីពីសវនាការដេញដោលលើឯកសារនាពេលខាងមុខ, កថាខណ្ឌ២-៦ (ផ្តល់នូវការជូនដំណឹងជាមុនស្តីពីសវនាការដេញដោលលើឯកសារនាពេលខាងមុខ និងពាក់ព័ន្ធនឹងឯកសារទាំងនេះ)។

23. ដើម្បីជួយសម្រួលដល់ការដាក់ជាឯកសារយោង អង្គជំនុំជម្រះបានភ្ជាប់ឯកសារទាំងអស់ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះជាមួយនឹងសេចក្តីសម្រេចនេះនៅក្នុងឧបសម្ព័ន្ធចំនួនបី រួមមានឧបសម្ព័ន្ធ ក (ទាក់ទងនឹងឯកសារដែលមានរៀបរាប់ក្នុងឧបសម្ព័ន្ធ A6-A11 និង A14-A20 របស់សហព្រះរាជអាជ្ញា) ឧបសម្ព័ន្ធ ខ (ទាក់ទងនឹងឯកសារដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានស្នើ) និងឧបសម្ព័ន្ធ គ (ទាក់ទងនឹងឯកសារដែល ខៀវ សំផន បានស្នើ និងឯកសារមួយដែល អៀង សារី បានស្នើ)។

**សម្រាប់សំអាងហេតុនានាដែលបានលើកឡើងខាងលើ អង្គជំនុំជម្រះសាលាដំបូង÷**

**ពិចារណាថា** ឯកសារទាំងអស់ដែលមាននៅក្នុងឧបសម្ព័ន្ធ A6-A11 និង A14-A20 របស់សហព្រះរាជអាជ្ញា ថាជាឯកសារដែលត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ [លើកលែងតែឯកសារចំនួនប្រាំពីរ ដែលត្រូវបានយោងនៅក្នុងឧបសម្ព័ន្ធ គ នៃសេចក្តីសម្រេចនេះ ដូចដែលបានបង្ហាញនៅក្នុងឧបសម្ព័ន្ធ (ឯកសារ E185/1.3)។

**ពិចារណាបន្ថែមថា** ឯកសារទាំងអស់ ដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានស្នើ ថាជាឯកសារដែលត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដូចដែលបានបង្ហាញនៅក្នុងឧបសម្ព័ន្ធ ខ នៃសេចក្តីសម្រេចនេះ (ឯកសារ E185/1.2)។

**ពិចារណាថា** ឯកសារទាំងអស់ដែល ខៀវ សំផន បានស្នើ ថាជាឯកសារដែលត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដូចដែលបានបង្ហាញនៅក្នុងឧបសម្ព័ន្ធ ក នៃសេចក្តីសម្រេចនេះ (ឯកសារ E185/1.1)។

**ពិចារណាបន្ថែមថា** ឯកសារ D222/1.17 ដែល អៀង សារី បានស្នើ ថាជាឯកសារដែលត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដូចដែលបានបង្ហាញនៅក្នុងឧបសម្ព័ន្ធ ក នៃសេចក្តីសម្រេចនេះ (ឯកសារ E185/1.1) និង



ទ. RR

**វិនិច្ឆ័យឡើងវិញថា** អង្គជំនុំជម្រះនឹងសម្រេចទៅលើតម្លៃ និងទម្ងន់នៃភស្តុតាងដែលត្រូវផ្ដល់ទៅឲ្យឯកសារទាំងអស់ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះដោយអានុភាពនៃសេចក្ដីសម្រេចនេះ នៅពេលបញ្ចប់សវនាការជម្រះលើភស្តុតាងក្នុងសំណុំរឿង ០០២/០១ នៅពេលពិចារណាចេញសាលក្រម។

ភ្នំពេញ, ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១២

ប្រធានអង្គជំនុំជម្រះសាលាដំបូង

និល ណុន